# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌលេខ ៥៨ "ជ១"ក្រ១១
ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ ១២២២
ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១
-សំណុំរឿងស៊ើបសួរលេខ ៩៦០
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២១
-សំណុំរឿងជំនុំជម្រះលេខ ៣៩៩៨
ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ០៩ : ០០ នាទី នៅសាលសវនាការទី២ ជាន់ទី១ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សាជំនុំជម្រះ
លោកស្រី ចៅក្រមប្រឹក្សាជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២២២ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] សុខហេង ហៅស្រីប៊ី ភេទស្រី អាយុ១៦ឆ្នាំ កើតថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៥ សញ្ជាតិខ្មែរ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ មានទីលំនៅមុខពេលឃុំខ្លួនស្នាក់នៅខាងរាំអូខេម្តប់ត្រជាក់ចិត្ត នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] សុខា "រស់" ជាអនីតិជនទោសពីមុនគ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២១៣៨ "ធ១" ដ.ឃ.ដ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២១ ដោយមានលោកស្រី [redacted] ស្រីទូច ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

ជាប់ចោទពីបទ ៖ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន**

ប្រព្រឹត្តនៅ ៖ រាជធានីភ្នំពេញ

កាលពី ៖ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២០

តាមបញ្ញត្តិ ៖ មាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២០ នៅចំណុចរាជធានីភ្នំពេញ មានករណីនាំយកចេញមិនស្របច្បាប់សម្រាប់នាំឆ្លងដែន (ឃោសនា បោកបញ្ឆោត នាំយកទៅប្រទេសចិន) ដែលបង្កឡើងដោយជនសង្ស័យ ៤



Scanned with CamScanner

ចំនួន ០២នាក់ មានឈ្មោះ [redacted] សុខហេង ហៅស្រីប៊ី ភេទស្រី អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី បាននាំជនរងគ្រោះឈ្មោះ [redacted] ស្រីនីត ភេទស្រី អាយុ ១៦ឆ្នាំ ចេញទៅប្រទេសចិន ដោយឆ្លងកាត់ប្រទេសវៀតណាម ដើម្បីរៀបការជាមួយបុរសជនជាតិចិន។ លុះដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១៥ និង ៣០នាទី កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សឆ្លងដែន សហការជាមួយស្នងការដ្ឋាននគរបាលកំពង់ស្ពឺ បានធ្វើការនាំខ្លួនជនសង្ស័យឈ្មោះ [redacted] សុខហេង ហៅស្រីប៊ី នៅចំណុចផ្លូវជាតិលេខ៤១ ស្ថិតនៅក្នុងភូមិត្រាំសសរ ឃុំស្វាយរំពារ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ មកសាកសួរនៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សឆ្លងដែន នៃក្រសួងមហាផ្ទៃតែម្តង ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៨៧៦ អ.យ.ត ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជម្រះលេខ ៥២៥៦ “ច១” ដ.ដ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុខហេង បានឆ្លើយថា៖ ទទួលស្គាល់ការចោទប្រកាន់ តែខ្លួនពុំបាននាំឈ្មោះ ស្រីនីត ទៅប្រទេសចិនទេ ខ្លួនបាននាំទៅឲ្យឈ្មោះ ចាន់ ស្នាក់នៅក្រុងតាខ្មៅ ហើយឈ្មោះ ចាន់ បានឲ្យប្រាក់មកខ្លួន ៥០ដុល្លារ ដោយសារឈ្មោះ នីត បានអាតមកខ្លួន ឲ្យជួយរកការងារធ្វើ តែខ្លួនប្រាប់ថាគ្មានទេ មានតែយកប្តីចិន បានថ្លៃទឹកដោះ ៣០០០ដុល្លារ ហើយឈ្មោះ នីត ចង់ទៅ ខ្លួនក៏បានប្រាប់ឲ្យសួរឪពុកម្តាយសិនទៅ តែវាថាឲ្យតែបានលុយម៉ែមិនថាអីទេ។ កន្លងមកខ្លួនធ្លាប់យកប្តីចិន បានថ្លៃទឹកដោះ ៣០០០ដុល្លារមែន ដោយឈ្មោះ ចាន់ ជាអ្នកនាំចេញតាមច្រកប្រទេសវៀតណាម តែពេលទៅដល់ចុះសំបុត្រអាពាហ៍ពិពាហ៍មិនបានដោយសារមិនទាន់គ្រប់អាយុ ទើបគេឲ្យមកវិញ រស់នៅទីនោះបាន ១ឆ្នាំ។ ពេលខ្លួននាំឈ្មោះ ស្រីនីត ឲ្យឈ្មោះ ចាន់ រួច ឈ្មោះ ចាន់ បានទូរស័ព្ទមកប្រាប់ខ្លួនថា វាមិនព្រមទៅទេ ខ្លួនក៏ប្រាប់វិញថាឲ្យវាជិះកង់បីមកវិញមកចឹង ប៉ុន្តែមួយអាទិត្យក្រោយមក ឈ្មោះ ស្រីនីត បានទូរស័ព្ទមកខ្លួនថា វានៅប្រទេសចិន ហើយចង់ត្រលប់មកផ្ទះវិញ ។

-ក្រឡាបញ្ជីអានអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីម ដែលបានឆ្លើយថា៖ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង១១ថ្ងៃត្រង់ កូនស្រីខ្លួនឈ្មោះ [redacted] ស្រីនីត ភេទស្រី អាយុ១៦ឆ្នាំ បានចេញពីផ្ទះបាត់ដំណឹងមិនដឹងទៅទីណា។ ប្រហែលជាកន្លះខែក្រោយមក កូនស្រីខ្លួនបានខ្ចីទូរសព្ទមេខ្យល់ (មិនចាំលេខទូរសព្ទ) មកជួបខ្លួនប្រាប់ថា កូនមកដល់ប្រទេសចិនហើយ ទៅតាមរយៈអ្នកណា កូនស្រីខ្លួនប្រាប់ថាកូនទៅជាមួយស្រីប៊ី ភេទស្រី និងបាននាំទៅអោយបងស្រីរបស់ឈ្មោះ ប៊ី នៅឯតាខ្មៅ ដោយធ្វើដំណើរឆ្លងកាត់តាមប្រទេសវៀតណាម (ឈ្មោះប៊ីមិន បានទៅជាមួយទេ) នៅពេលដែលទៅដល់កូនស្រីខ្លួនមកស្នាក់ផ្ទះនៅមេខ្យល់ម្នាក់ទៀតជាជនជាតិខ្មែរ ប្តីជាជនជាតិចិន (មិនស្គាល់ឈ្មោះ) បន្ទាប់មកមេខ្យល់នាំជនជាតិចិនមកមើលកូនស្រីខ្លួនដល់ផ្ទះ ហើយក៏ពេញចិត្តកូនស្រីខ្លួនយកធ្វើជាប្រពន្ធ ក្រោយមកទៀតក៏ប្រាប់ខ្លួនអោយជួយកូនខ្លួនមកប្រទេសកម្ពុជាវិញ ដោយសារមានជម្ងឺរោគស្ត្រី។ លុះមកដល់ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១ កូនស្រីខ្លួនម្នាក់ទៀតឈ្មោះ [redacted] លីដា បានមកទំនាក់ទំនងជាមួយអ្នកកាសែតឈ្មោះ បងពេជ្រ សារព័ត៌មាន២៤ម៉ោង បន្ទាប់មកអ្នកសារព័ត៌មានក៏មកដល់ផ្ទះខ្លួន រួចគាត់ក៏សាកសួររឿងហេតុរបស់កូនស្រីខ្លួនប្រាប់គាត់ ហើយគាត់ឱ្យខ្លួនថតចម្លងដូចជា សំបុត្រកំណើត សៀវភៅស្នាក់នៅ រូបថតកូនស្រីខ្លួនយកមកអោយគាត់ លុះមកដល់ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង០៧ព្រឹក គាត់បានមកនាំខ្លួនមកផ្ទះមេរបស់គាត់អោយខ្លួនធ្វើលិខិតអន្តរាគមន៍ដល់



Scanned with CamScanner

សម្តេចនាយករដ្ឋមន្ត្រី លុះមកដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង១៥ និង០០នាទី គាត់ក៏អោយខ្លួនដាក់ពាក្យបណ្តឹងនៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។

-ក្រឡាបញ្ជីអានអំណានចម្លើយបំភ្លឺរបស់ឈ្មោះ [redacted]ម្លូរ៉ា ដែលបានឆ្លើយថា៖ កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១០ព្រឹក មានស្ត្រីម្នាក់ឈ្មោះ [redacted] ស៊ីម អាយុប្រហែល៤៣ឆ្នាំ មានអាសយដ្ឋានភូមិតាស្គរ ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្តាល បានទូរស័ព្ទមកខ្លួនតាមរយៈលេខ ០៨១ ៣៩៧ ៧៣៩ សុំអោយខ្លួនជួយផ្សព្វផ្សាយព័ត៌មានកូនស្រីរបស់គាត់ឈ្មោះ [redacted] ស្រីនីត អាយុ១៦ឆ្នាំ ដែលត្រូវបានមេខ្យល់មិនស្គាល់ឈ្មោះ ភេទស្រី អាយុប្រហែល១៩ឆ្នាំ ប្រើគណនីហ្វេសប៊ុកឈ្មោះ [redacted] Bee បានឃោសនាអូសទាញកូនស្រីគាត់នាំយកទៅលក់ឱ្យបុរសជនជាតិចិន រស់នៅប្រទេសចិនធ្វើជាប្រពន្ធ បច្ចុប្បន្នកូនស្រីរបស់គាត់បានទៅដល់ប្រទេសចិនហើយ ត្រូវបានមេខ្យល់លក់ទៅឱ្យបុរសជនជាតិចិនជាបន្តបន្ទាប់ក្នុងតម្លៃ១២ម៉ឺនលុយចិន ហើយបង្ខំឱ្យរួមភេទ ប្រើអំពើហិង្សា បិទសិទ្ធិសេរីភាព និងឃុំខ្លួនទុកនៅក្នុងផ្ទះ។ នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៨យប់ ខ្លួនបានឆាតទៅគណនីហ្វេសប៊ុកឈ្មោះ [redacted] Bee ធ្វើជាសុំរាប់អានគ្នា ដោយម្ចាស់គណនីហ្វេសប៊ុកនោះជាមនុស្សស្រី ពេលនោះខ្លួនក៏បានសុំលេខទូរសព្ទ ហើយម្ចាស់គណនីហ្វេសប៊ុកឈ្មោះ [redacted] Bee បានអោយលេខទូរសព្ទមកខ្លួនដែលមានលេខ ០៩៦៤ ៣២៣ ៦១២ រួចខ្លួនក៏បានទូរសព្ទទៅនិយាយធ្វើជាសុំស្រលាញ់ ហើយខ្លួនបានផ្ញើលុយ ចំនួន១២ម៉ឺនរៀលឱ្យចាយតាមរយៈវីង ដែលមានលេខកូដ (៣៧៥៦៩៩៨៩)។ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៤រសៀល ម្ចាស់គណនីហ្វេសប៊ុកឈ្មោះ [redacted] Bee បានឆាតមកខ្លួននិយាយលេង រួចខ្លួនក៏សុំឈ្មោះតែគេមិនឱ្យ និងបានសុំទូរស័ព្ទខ្លួនមួយគ្រឿងម៉ាក Iphone 11Pro បើខ្លួនព្រមទិញទូរសព្ទឱ្យទើបគេស្រឡាញ់ និងបានឆាតមើលមុខគ្នាពេលនោះខ្លួនបានថតរូប ស្ត្រីនោះបាន រួចខ្លួនបានសន្យាថានៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងបំហែល១២ថ្ងៃ ត្រង់ណាត់ជួបគ្នានៅផ្សារព្រែកព្នៅ ដើម្បីទិញទូរសព្ទអោយ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ជនជាប់ចោទបានឆ្លើយសារភាពថាខ្លួនជាអ្នកណែនាំឱ្យជនរងគ្រោះទៅប្រទេសចិន និងបានជូនជនរងគ្រោះទៅជួបឈ្មោះ ចាន់ ហើយជនរងគ្រោះបានទៅដល់ប្រទេសចិនមែន និងបានបញ្ជាក់ថា ខ្លួនបានដឹងពីការនាំជនរងគ្រោះទៅប្រទេសចិន និងបានទំនាក់ទំនងជាមួយជនរងគ្រោះនៅពេលជនរងគ្រោះទៅដល់ប្រទេសចិនទៀតផង ដូច្នេះ ស្នើសុំរក្សាការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៨៧៦ អ.យ.ត ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ឆ្លងកាត់ការស្តាប់ចម្លើយរបស់កូនក្តីខ្លួន និងពិនិត្យលើឯកសារពាក់ព័ន្ធនានា អាចបញ្ជាក់បានថា កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តបទល្មើសតាមការចោទប្រកាន់ទេ ដោយកូនក្តីខ្លួនគ្រាន់តែបានប្រាប់ទៅជនរងគ្រោះ ថាស្គាល់នារីម្នាក់ឈ្មោះ ចាន់ ដែលជាអ្នកនាំគេឱ្យយកប្តីចិន ហើយឈ្មោះ [redacted] ស្រីនីត យល់ព្រមទៅដោយខ្លួនឯង បើសិនកូនក្តីខ្លួនមានចេតនាទុច្ចរិតមែន កូនក្តីខ្លួនទាក់ទងជាមួយជនរងគ្រោះធ្វើអ្វី ដូចនេះ សរុបសេចក្តីមក សកម្មភាពរបស់កូនក្តីខ្លួនពុំមានធាតុផ្សំគ្រប់គ្រាន់ ដើម្បីចាត់ទុកជាការប្រព្រឹត្តបទល្មើសទេ ហើយអំពើរបស់កូនក្តីខ្លួនមិនអាចចាត់ទុកជាការនាំចេញមិនស្របច្បាប់បានទេ ដោយសារកូនក្តីខ្លួនមិនបានដឹងពីដំណាក់កាលដែលឈ្មោះ ចាន់ នាំយកជនរងគ្រោះទៅដោយរបៀបណាទេ គ្រាន់តែនាំជនរងគ្រោះទៅជួបឈ្មោះ ចាន់ ហើយកូនក្តីខ្លួនក៏ធ្លាប់បានឈ្មោះ ចាន់ នាំយកទៅម្តងរួចហើយដែរ ហេតុនេះកូនក្តីខ្លួនក៏ជាជនរងគ្រោះដែរ ម្យ៉ាងទៀតកូនក្តីខ្លួនជាអនីតិជន មានជីវភាពខ្វះខាត និងរៀនសូត្របានតិចតួច ខ្វះការអប់រំ ហេតុនេះស្នើសុំឱ្យតុលាការពិចារណា និងលើកលែងបទចោទមកលើកូនក្តីរបស់ខ្លួនឈ្មោះ [redacted]សុខហេង ហៅស្រីប៊ី និងសម្រេចដោះលែងឱ្យកូនក្តីខ្លួនមានសេរីភាពឡើងវិញ ។ ៚

## សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុខហេង ហៅស្រីប៊ី បានស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជម្រះលេខ ៥២៥៦ "ច១" ង.ង ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនឈ្មោះ [redacted] សុខហេង ហៅស្រីប៊ី ភេទស្រី អាយុ១៦ឆ្នាំ ទៅជំនុំជម្រះពីបទ៖ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខហេង ហៅស្រីប៊ី នាពេលសវនាការឃើញថាជនជាប់ចោទបានសារភាពថាខ្លួនជាអ្នកនាំជនរងគ្រោះទៅឱ្យឈ្មោះ ចាន់ នៅតាខ្មៅមែន ប៉ុន្តែខ្លួនមិនបានលួងលោម ឬបោកបញ្ឆោតទេ គឺឈ្មោះ នីត ទាក់ទងខ្លួនរកការងារឱ្យ តែខ្លួនបានប្រាប់រឿងខ្លួនទៅការប្ដីចិនបានថ្លៃទឹកដោះ ៣០០០ដុល្លារអាមេរិក។ ឈ្មោះ នីត ចង់ទៅខ្លួនឯង ទើបឱ្យជូនទៅ ហើយឈ្មោះ ចាន់ ឱ្យខ្លួន ៥០ដុល្លារអាមេរិក។ នៅពេលជនរងគ្រោះទៅដល់បានទំនាក់ទំនងឱ្យខ្លួនជួយដើម្បីបានត្រលប់មកផ្ទះវិញ តែខ្លួនបានប្រាប់ថាឱ្យនៅបន្ត ដើម្បីបានសោហ៊ុយត្រឡប់មកវិញ។

៣-តាមអំណានចម្លើយរបស់ដើមបណ្ដឹងឈ្មោះ [redacted] ស៊ីម បានឆ្លើយថា៖ ដំបូងឡើយកូនខ្លួនឈ្មោះ [redacted] ស្រីនីត ភេទស្រី អាយុ ១៦ឆ្នាំ បានទូរស័ព្ទប្រាប់ខ្លួនថា គាត់នៅប្រទេសចិនដោយគេនាំមកលក់ឱ្យជនជាតិចិន ដើម្បីឱ្យធ្វើជាប្រពន្ធគេ ពេលដឹងរឿងបែបនេះ ទើបខ្លួនទៅដាក់ពាក្យបណ្ដឹងនៅសមត្ថកិច្ចដើម្បីជួយអន្តរាគមន៍ ហើយបច្ចុប្បន្នកូនស្រីខ្លួនបានត្រឡប់មកវិញរយៈពេលជាងមួយខែហើយ ។

៤-យោងតាមមាត្រា ១១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ បានបញ្ញត្តិពីបទ ***ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន*** ថា "*ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬ នាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្ដន្ទាទោស...................... ។ ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅប្រគល់ ឬ នាំជននោះទៅប្រទេសផ្សេងទៀត ត្រូវផ្ដន្ទាទោស...................... ។ ត្រូវផ្ដន្ទាទោស...................... ក្នុងដែលជនរងគ្រោះជាអនីតិជន......................................................* ។ " ដូច្នេះឃើញថាសកម្មភាពរបស់ជនជាប់ចោទដែលបានប្រព្រឹត្តគឺបាននាំយកជនរងគ្រោះឈ្មោះ [redacted] ស្រីនីត ជាអនីតិជន ចេញពីប្រទេសកម្ពុជាទៅប្រទេសចិនដោយមិនស្របច្បាប់ ដូច្នេះតុលាការគប្បីពិចារណា ។

៥-តាមចម្លើយរបស់ជនជាប់ចោទ នៅគ្រប់ដំណាក់កាលនៃនីតិវិធី និងភស្តុតាងផ្សេងៗ ឃើញថាមានភាពស៊ីចង្វាក់គ្នាដែលអាចបញ្ជាក់បានថា៖ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២០ ពិតជាមានករណី **ការនាំចេញដោយមិនស្រប** ៤



Scanned with CamScanner

ច្បាប់សម្រាប់នាំឆ្លងដែន ប្រព្រឹត្តនៅរាជធានីភ្នំពេញ តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលប្រព្រឹត្តដោយឈ្មោះ [redacted]សុខហេង ហៅស្រីប៉ី ប្រាកដមែន។

-សកម្មភាពរបស់ជនជាប់ចោទ គឺបាននាំជនរងគ្រោះឈ្មោះ [redacted] ស្រីនីត ទៅឱ្យឈ្មោះ ចាន់ ដើម្បីនាំឆ្លងដែនទៅប្រទេសចិន រៀបការជាមួយបុរសចិន ។

៦-ការប្រព្រឹត្តអំពើល្មើសរបស់ជនជាប់ចោទធ្វើឡើងដោយមានចេតនា និងមានស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ និងជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ក៏ដូចជាធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ហើយបំពានទៅលើនីត្យានុកូលភាពសង្គម ដែលច្បាប់បានការពារយ៉ាងម៉ឺងម៉ាត់បំផុត។

៧-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ លេខ ៣៨៧៦ អ.យ.ត ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ព្រោះមានចម្លើយ និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ការប្តឹងសុំនេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់កំណត់ ។

៨-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សុខហេង ហៅស្រីប៉ី ពីបទ៖ **ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៩-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា អំពើរបស់កូនក្តីខ្លួនមិនអាចចាត់ទុកជាការនាំចេញមិនស្របច្បាប់បានទេ ដោយសារកូនក្តីខ្លួនមិនបានដឹងពីដំណាក់កាលដែលឈ្មោះ ចាន់ នាំយកជនរងគ្រោះទៅដោយរបៀបណាទេ គ្រាន់តែនាំជនរងគ្រោះទៅជួបឈ្មោះ ចាន់ ហើយកូនក្តីខ្លួនក៏ធ្លាប់បានឈ្មោះ ចាន់ នាំយកទៅម្តងរួចហើយដែរ ហេតុនេះកូនក្តីខ្លួនក៏ជាជនរងគ្រោះដែរ ម្យ៉ាងទៀតកូនក្តីខ្លួនជាអនីតិជន មានជីវភាពខ្វះខាត និងរៀនសូត្របានតិចតួចខ្វះការអប់រំ ហេតុនេះស្នើសុំឱ្យតុលាការពិចារណា និងលើកលែងបទចោទមកលើកូនក្តីរបស់ខ្លួន ។

១០-ជនជាប់ចោទរូបនេះ ជាអនីតិជន ដែលមានអាយុទើបតែ ១៦ឆ្នាំ ហើយធ្លាប់ត្រូវបានឈ្មោះ ចាន់ ណែនាំឱ្យទៅយកប្តីចិន ដើម្បីទទួលបានថ្លៃទឹកដោះចំនួន ៣០០០ដុល្លារអាមេរិក នេះបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទខ្វះការអប់រំ និងមានជីវភាពខ្វះខាតប្រាកដមែន ហេតុនេះតុលាការគប្បីពិចារណាអំពីស្ថានសម្រាល និងអនុវត្តទោសចំពោះអនីតិជន ស្របតាមមាត្រា ៩៣ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

១១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ស៊ីម បានដកពាក្យបណ្តឹងឈប់ប្តឹងតទៅទៀតហើយ ហេតុនេះតុលាការមិនពិចារណា និងសម្រេចអំពីសំណងរដ្ឋប្បវេណីទេ ។

១២-តាមកំណត់ហេតុទទួលវត្ថុចាប់យក(១) លេខ ៥៩៤ រ.វ.ត ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ មាន៖ ទូរស័ព្ទដៃចំនួន០១គ្រឿង ម៉ាក OPPO ពណ៌ខ្មៅ (មិនដំណើរការ) គប្បីតុលាការសម្រេចរឹបអូសតាមច្បាប់ ។

## <u>ហេតុដូច្នេះសម្រេច</u>

**១.ផ្តន្ទាទោសលើឈ្មោះ [redacted] សុខហេង ហៅស្រីប៉ី ភេទស្រី អាយុ១៦ឆ្នាំ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ៣ (បី) ឆ្នាំ និង ៦ (ប្រាំមួយ) ខែ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារចំនួន ១ (មួយ) ឆ្នាំ និង ៦ (ប្រាំមួយ) ខែ ទោសសល់ពីនេះត្រូវព្យួរធម្មតា ។**

ពីបទ៖ **ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។



Scanned with CamScanner

២.វត្ថុចាប់យកត្រូវរឹបអូសរួមមាន៖

-ទូរស័ព្ទដៃចំនួន០១គ្រឿង ម៉ាក OPPO ពណ៌ខ្មៅ (មិនដំណើរការ) ។

សាលក្រមនេះ ជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ។

រក្សាសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]